THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Tony B. Watlington Sr., Ed.D.**
Superintendent

ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០២៤

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

**ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការប្រកាសថា ការចុះឈ្មោះសម្រាប់កម្មវិធីក្នុងរដូវក្តៅរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឥឡូវនេះបើកសម្រាប់សិស្សថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២។ ចុចទីនេះ ដើម្បីចុះឈ្មោះនៅថ្ងៃនេះ!**

កម្មវិធីក្នុងរដូវក្តៅនៅឆ្នាំនេះរួមមានកម្មវិធីថ្មីៗដ៏គួរឱ្យរំភើប ដូចជា ការអប់រំផ្នែកអាជីព និងបច្ចេកទេស ជំរុំក្នុងរដូវក្តៅ និងអ្នកសម្រេចជោគជ័យក្នុងរដូវក្តៅ (Summer Camp and Summer Achievers)។ កម្មវិធីក្នុងរដូវក្តៅរបស់យើងផ្តល់នូវបរិយាកាសរីករាយ និងមានសុវត្ថិភាព ដើម្បីសិស្សានុសិស្សរក្សា និងជំរុញការសិក្សារបស់ពួកគេ។ កម្មវិធីក្នុងរដូវក្តៅក៏ជួយយុវវ័យរបស់យើងឱ្យរក្សានូវជំនាញសំខាន់ៗ ដែលពួកគេបានរៀនក្នុងអំឡុងឆ្នាំសិក្សា។

កម្មវិធីដ៏ទូលំទូលាយផ្តល់នូវជម្រើសសម្រាប់សិស្សរបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា គ្រប់វ័យ – ពីការសិក្សាដែលពង្រឹងនូវចំណេះដឹង ដល់ឱកាសធ្វើការងារក្នុងរដូវក្តៅសម្រាប់សិស្សវិទ្យាល័យ។ លើសពីនេះ ការិយាល័យផ្នែកកុមារ និងក្រុមគ្រួសារ របស់ទីក្រុងហ្វីឡាដែលហ្វ្យ៉ា ផ្តល់កម្មវិធីក្នុងរដូវក្តៅពេញថ្ងៃ តាមរយៈនៃការផ្តួចផ្តើមថ្មី កម្មវិធី Summer Achievers ហើយ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ផ្តល់នូវផ្នែកសិក្សានៃកម្មវិធី Summer Achievers។ ដើម្បីស្វែងយល់បន្ថែមអំពីកម្មវិធីផ្សេងៗដែលមាន និងចុះឈ្មោះចូលរួម សូមចូលទៅកាន់គេហទំព័រកម្មវិធីក្នុងរដូវក្តៅ នៅទីនេះ។

សិស្សរបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បច្ចុប្បន្នទាំងអស់ រួមទាំងសិស្សដែលនឹងចូលរៀនថ្នាក់មត្តេយ្យនៅរដូវស្លឹកឈើជ្រុះនេះ មានសិទ្ធិ ហើយជំរុញឱ្យចុះឈ្មោះសម្រាប់កម្មវិធីក្នុងរដូវក្តៅ។ កៅអីសម្រាប់កម្មវិធីក្នុងរដូវក្តៅមានកំណត់ ហើយការចុះឈ្មោះមិនធានាថាអាចចូលរួមបានទេ។ ការចុះឈ្មោះសម្រាប់កម្មវិធីភាគច្រើនបើកនៅថ្ងៃទី ១ ខែមេសា ហើយបិទនៅថ្ងៃទី ១០ ខែឧសភា។ ក្រុម

គ្រួសារ និងសិស្ស នឹងទទួលដំណឹងអំពីស្ថានភាពចុះឈ្មោះរបស់ពួកគេមិនហួសពីថ្ងៃទី ៣១ ខែឧសភា។ សូមពិនិត្យមើលព័ត៌មានជាក់លាក់អំពីកម្មវិធី នៅទីនេះ។

ខ្ញុំសង្ឃឹមថា លោកអ្នកនឹងពិចារណាដល់ ការចុះឈ្មោះនៅថ្ងៃនេះ registering today ដើម្បីផ្តល់ឱកាសឱ្យកូនរបស់លោកអ្នកទទួលបាននូវបទពិសោធន៍បន្ថែម និងមានអត្ថន័យ ក្នុងរដូវក្តៅនេះ។ ការចុះឈ្មោះសម្រាប់កម្មវិធីភាគច្រើនបើកពីឥឡូវនេះរហូតដល់ថ្ងៃទី ១០ ខែឧសភា ប៉ុន្តែសូមពិនិត្យមើល គេហទំព័រសម្រាប់កម្មវិធីក្នុងរដូវក្តៅ Summer Programs website ដើម្បីព័ត៌មានលម្អិតអំពីកម្មវិធី និងព័ត៌មានសម្រាប់ទាក់ទង។

កម្មវិធីក្នុងរដូវក្តៅគឺជាវិធីមួយដែលក្រសួងអប់រំធ្វើសកម្មភាពតាមការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការរៀបចំក្មេងរបស់យើងឱ្យស្រមើស្រមៃ និងសម្រេចបាននូវអនាគតដែលពួកគេប្រាថ្នាចង់បាន។

ក្នុងភាពជាដៃគូ



Tony B. Watlington Sr., Ed.D.
អគ្គនាយកនៃក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា